**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជា ឆ្នាំ២០១៥

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងចំពោះសាធារណជន កម្មករនិយោជិត អង្គការវិជ្ជាជីវៈ និយោជក អង្គការជាតិ និងអន្តរជាតិទាំងអស់ឱ្យបានជ្រាបថា ក្នុងឆ្នាំ២០១៤ នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានសហការជាមួយអង្គការអន្តរជាតិខាងការងារ (ILO) ដើម្បីពង្រឹងយន្តការ នីតិវិធី និងលក្ខណវិនិច្ឆ័យក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជា។ តាមរយៈកិច្ចសហការនេះ អង្គការ ILO បានរៀបចំឱ្យមានសិក្ខាសាលាត្រីភាគីថ្នាក់ជាតិចំនួន ២លើក ដោយទទួលបានលទ្ធផលវិជ្ជមានជាច្រើនដាក់ជូនគណៈកម្មការប្រឹក្សាការងារពិនិត្យសម្រេច។ គណៈកម្មការប្រឹក្សាការងារបានសម្រេចនូវយន្តការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ដូចខាងក្រោម៖

-កំណត់យកលក្ខណវិនិច្ឆ័យបែបសង្គម (ស្ថានភាពគ្រួសារ អត្រាអតិផរណា និងការចំណាយក្នុងការរស់នៅ) និងលក្ខណវិនិច្ឆ័យបែបសេដ្ឋកិច្ច (ផលិតភាព ភាពប្រកួតប្រជែង ស្ថានភាពទីផ្សារការងារ និងកម្រិតតម្លៃបន្ថែមនៃវិស័យ) ក៏ដូចជាបន្ទាត់ភាពក្រីក្រជាមូលដ្ឋានក្នុងការពិភាក្សាប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា។

-កំណត់ឱ្យមានការប្រជុំពិភាក្សាប្រាក់ឈ្នួលអប្បបរមាជារៀងរាល់ឆ្នាំ ដោយធ្វើការប្រជុំផ្ទៃក្នុងរបស់ភាគីនីមួយៗនៅខែកក្កដា ប្រជុំទ្វេភាគីនៅខែសីហា ប្រជុំត្រីភាគីនៅខែកញ្ញា និងប្រជុំសម្រេចប្រាក់ឈ្នួលអប្បបរមានៅខែតុលា។

-កំណត់យកនីតិវិធីសម្រេចចិត្តរបស់គណៈកម្មការប្រឹក្សាការងារ ដោយការបោះឆ្នោតសម្ងាត់ និងតាមសំឡេងភាគច្រើន ក្នុងករណីមិនទទួលបានការឯកភាពជាឯកច្ឆ័ន្ទក្នុងកិច្ចប្រជុំពីរផ្សេងគ្នា។

ជាមួយគ្នានេះដែរ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈក៏បានបង្កើតឱ្យមានក្រុមការងារត្រីភាគីដែលមានតំណាងភាគីនិយោជកចំនួន ៩រូប តំណាងភាគីកម្មករនិយោជិតចំនួន ៩រូប និងតំណាងភាគីរាជរដ្ឋាភិបាលចំនួន ៩រូប ដើម្បីពិភាក្សាអំពីប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងដែលមានលក្ខណៈទូលំទូលាយ មានទិន្នន័យច្បាស់លាស់ និងមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិភាក្សា។ បន្ទាប់ពីកិច្ចប្រជុំជាច្រើនលើក ក្រុមការងារត្រីភាគីបានបោះឆ្នោតជាសម្ងាត់ដោយយកសំឡេងភាគច្រើនតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ ជ្រើសរើសយកតួលេខ ១២១ ដុល្លារអាមេរិក និងតួលេខ ១១០ ដុល្លារអាមេរិក ដើម្បីដាក់ជូនគណៈកម្មការប្រឹក្សាការងារពិនិត្យពិភាក្សាបន្ត។

កាលពីព្រឹកថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៤ គណៈកម្មការប្រឹក្សាការងារបានបើកកិច្ចប្រជុំការងារអាណត្តិទី៨ លើកទី១១ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិនិត្យពិភាក្សាលើលទ្ធផលរបស់ក្រុមការងារត្រីភាគី និងធ្វើការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ឆ្នាំ២០១៥ ប៉ុន្តែមិនទទួលបានការគាំទ្រជាឯកច្ឆ័ន្ទលើតួលេខណាមួយឡើយ ព្រោះភាគីនិយោជកនៅរក្សាជំហរ ១១០ ដុល្លារអាមេរិក ហើយភាគីសហជីពនៅតែរក្សាគោលជំហរ ១៤០ ដុល្លារអាមេរិកដដែល។ ដើម្បីសម្របសម្រួលរវាងភាគីទាំងពីរ ភាគីរាជរដ្ឋាភិបាលបានស្នើដាក់តួលេខ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

ចំនួន ១២៣ ដុល្លារអាមេរិក ជូនគណៈកម្មការប្រឹក្សាការងារពិនិត្យសម្រេច។ គណៈកម្មការប្រឹក្សាការងារបានបោះឆ្នោតជាសម្ងាត់លើតួលេខទាំង៣ ដោយទទួលបានលទ្ធផលដូចខាងក្រោមៈ

-តួលេខចំនួន ១១០ ដុល្លារអាមេរិក ទទួលបានសំឡេងឆ្នោត ០៧ លើ ២៥។

-តួលេខចំនួន ១២៣ ដុល្លារអាមេរិក ទទួលបានសំឡេងឆ្នោត ១៦ លើ ២៥។

-តួលេខចំនួន ១៤០ ដុល្លារអាមេរិក ទទួលបានសំឡេងឆ្នោត ០២ លើ ២៥។

ដូច្នេះ គណៈកម្មការប្រឹក្សាការងារបានស្នើតួលេខចំនួន ១២៣ (មួយរយម្ភៃបី) ដុល្លារអាមេរិក ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើការពិនិត្យសម្រេចលើប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ឆ្នាំ២០១៥។

យោងតាមរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែយកចិត្តទុកដាក់អំពីសុខុមាលភាព និងជីវភាពរស់នៅសមរម្យរបស់កម្មករនិយោជិត និងផលិតភាពរបស់រោងចក្រសហគ្រាស គ្រឹះស្ថាន បានសម្រេចបន្ថែមទឹកប្រាក់ចំនួន ៥ (ប្រាំ) ដុល្លារអាមេរិកលើចំនួនទឹកប្រាក់ចំនួន ១២៣ (មួយរយម្ភៃបី) ដុល្លារអាមេរិក ដែលបានស្នើដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ហេតុនេះ ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ឆ្នាំ២០១៥ មានចំនួន ១២៨ (មួយរយម្ភៃប្រាំបី) ដុល្លារអាមេរិកក្នុងមួយខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ តទៅ។

ទន្ទឹមនឹងនេះ ប្រាក់អត្ថប្រយោជន៍ផ្សេងទៀត ដែលកម្មករនិយោជិតធ្លាប់ទទួលបានកន្លងមក ត្រូវបានរក្សាទុកដដែល មានដូចជាប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅចំនួន ៧ដុល្លារអាមេរិកក្នុងមួយខែ ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ដុល្លារអាមេរិកក្នុងមួយខែ ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងដោយស្ម័គ្រចិត្តចំនួន ២០០០រៀលក្នុងមួយថ្ងៃ ឬទទួលបានបាយមួយពេលដោយឥតគិតថ្លៃ និងប្រាក់រង្វាន់អតីតភាពការងារចំនួន ២ដុល្លារអាមេរិក ដល់ ១១ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់កម្មករនិយោជិតដែលបានធ្វើការចាប់ពីឆ្នាំទី២ ដល់ឆ្នាំទី១១។ ដូច្នេះ ជាមធ្យមកម្មករនិយោជិតម្នាក់នឹងទទួលបានប្រាក់បៀវត្សយ៉ាងតិចចំនួន ១៤៧ ដុល្លារអាមេរិកដល់ ១៥៦ ដុល្លារអាមេរិកក្នុងមួយខែ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានសម្រេចផ្តល់ប្រាក់បន្ថែមចំនួន ៥ ដុល្លារអាមេរិក សម្រាប់ការដំឡើងប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០១៥ នេះ ដែលធ្វើឱ្យស្ថានភាពជីវភាពរបស់បងប្អូនកម្មករនិយោជិត កាន់តែមានភាពល្អប្រសើរឡើងជាងមុន ហើយក៏ជាកត្តាដ៏សំខាន់ក្នុងការជំរុញផលិតភាពផងដែរ។

ក្រសួងក៏សូមថ្លែងអំណរគុណដល់អង្គការ ILO ដែលបានផ្តល់នូវកិច្ចសហការដ៏ជិតស្និទ្ធដល់ក្រសួងក្នុងការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងនៅកម្ពុជា។ ជាមួយគ្នានេះដែរ ក្រសួងក៏សូមថ្លែងអំណរគុណដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមយ៉ាងសកម្មក្នុងការដោះស្រាយបញ្ហាប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែក វាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ឆ្នាំ២០១៥។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន កម្មករនិយោជិត អង្គការវិជ្ជាជីវៈគ្រប់ជាន់ថ្នាក់ និយោជក អង្គការជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មានតាមការគួរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤